Click here for English version

PERSONAL BANKING

# ផ្តល់ជូនកូនៗលោកអ្នក នូវការអប់រំមួយដ៏ស័ក្តិសម

គ្រប់គ្រងចំណាយសាកលវិទ្យាល័យ
ជាមួយកម្ចីបង់រំលស់ប្រចាំខែដ៏សមរម្យ



BRED BANK CAMBODIA | ADVANCE

## បង់ថ្លៃសាលាជាមុន បែងចែកចំណាយជាក្រោយ

សម្រាប់ឪពុកម្តាយជុំវិញពិភពលោក គ្មានអ្វីដែលសំខាន់ជាងការប្រាកដថាកូនៗរបស់ពួកគេទទួលបានការអប់រំដ៏ល្អបំផុតតាមដែលអាចធ្វើបាននោះទេ។ យើងខ្ញុំយល់ស្រប ព្រមទាំងទទួលស្គាល់ថាវាជាការប្តេជ្ញាផ្នែកហិរញ្ញវត្ថុដ៏ធំមួយ ហើយនេះក៏ជាមូលហេតុដែលយើងខ្ញុំបានបង្កើតដំណោះស្រាយកម្ចីបង់រំលស់ថ្លៃសាកលវិទ្យាល័យ ADVANCE។

វាជាប្រភេទកម្ចីបង់រំលស់លក្ខណៈបុគ្គលរបស់ធនាគារ ប្រេដ ខេមបូឌា ដែលផ្តល់ភាពងាយស្រួលដល់ការបង់ថ្លៃសាកលវិទ្យាល័យប្រចាំខែរបស់កូនលោកអ្នកក្នុងតម្លៃសមរម្យ។

- ✓ **ដំណើរការស្នើសុំកម្ចីមានភាពងាយស្រួល និងរហ័ស**
- ✓ **កម្ចីមានទាំងថ្លៃសាលា ថ្លៃស្នាក់នៅ និងថ្លៃផ្សេងៗទៀត ដែលសងវិញដោយការបង់រំលស់ជាខែ**
- ✓ **កម្ចីមិនមានទ្រព្យធានារហូតដល់ 15,000 ដុល្លារ ឬច្រើនជាងនេះទៀតជាមួយកម្ចីមានទ្រព្យធានា**

## ងាយស្រួលក្នុងស្នើសុំ

រាល់ពាក្យស្នើសុំកម្ចីបង់រំលស់ថ្លៃសាកលវិទ្យាល័យ ADVANCE គឺត្រូវបានពិចារណាទៅតាមគុណតម្លៃរបស់វា។ ក្រុមការងាររបស់យើងខ្ញុំនឹងខិតខំប្រឹងប្រែងយកតម្រូវការទាំងអស់របស់អ្នកមកពិចារណា មុននឹងកែសម្រួលជាដំណោះស្រាយដែលល្អបំផុតដើម្បីបំពេញតាមតម្រូវការ និងកញ្ចប់ថវិការបស់អ្នក។

ទូរសព្ទឥឡូវនេះ

## ឧទាហរណ៍

### កម្ចីបង់រំលស់ថ្លៃសាកលវិទ្យាល័យ ADVANCE មានទ្រព្យធានា

ស្រីពេជ្រ ចង់ទៅរៀននៅបរទេស។ ដើម្បីគាំទ្រក្តីស្រមៃរបស់គាត់ ឪពុកម្តាយរបស់គាត់បានស្នើសុំកម្ចីមានទ្រព្យធានាចំនួន 100,000 ដុល្លារ ដោយតម្កល់ផ្ទះរបស់ពួកគេ ហើយពួកគាត់នឹងធ្វើការសងវិញក្នុងរយៈពេល 7 ឆ្នាំ។

| ចំនួនទឹកប្រាក់កម្ចី៖ | 100,000 ដុល្លារ |
|---|---|
| ចំនួនបង់ប្រចាំខែក្នុងរយៈពេល 84 ខែ៖ | 1,584 ដុល្លារ |
| **ការប្រាក់សរុប៖** | **33,026 ដុល្លារ** |

លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត។ កម្ចីជាកម្មវត្ថុនៃការអនុម័ត និងត្រូវមានទ្រព្យធានា។ កម្ចីមានរយៈពេល រហូតដល់ 15 ឆ្នាំ។ អត្រាការប្រាក់ជាធម្មតាពី 8% ទៅ 9% ។ ថ្លៃសេវារៀបចំប្រាក់កម្ចីត្រូវបានអនុវត្ត។

### កម្ចីបង់រំលស់ថ្លៃសាកលវិទ្យាល័យ ADVANCE គ្មានទ្រព្យធានា

ម៉ូលីកា ចូលរៀននៅសាកលវិទ្យាល័យក្នុងប្រទេសអូស្ត្រាលី។ ឪពុកម្តាយរបស់គាត់បង់ថ្លៃសាលារបស់គាត់ដោយប្រើប្រាក់សន្សំដែលមានស្រាប់ ប៉ុន្តែពួកគាត់សម្រេចចិត្តប្រើកម្ចីបង់រំលស់ថ្លៃសាកលវិទ្យាល័យ ADVANCE ដើម្បីរ៉ាប់រងថ្លៃស្នាក់នៅរបស់នាង។

| ចំនួនទឹកប្រាក់កម្ចី៖ | 12,000 ដុល្លារ |
|---|---|
| ចំនួនបង់ប្រចាំខែក្នុងរយៈពេល 84 ខែ៖ | 1,100 ដុល្លារ |
| **ការប្រាក់សរុប៖** | **1,202 ដុល្លារ** |

លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត។ កម្ចីជាកម្មវត្ថុនៃការអនុម័ត និងអត្រាការប្រាក់ជាធម្មតា 18%។ ថ្លៃសេវារៀបចំប្រាក់កម្ចីត្រូវបានអនុវត្ត។

## របៀបស្នើសុំកម្ចី

ដំណើរការសំណើរបស់យើងខ្ញុំគឺមានភាពរហ័ស និងត្រូវបានរក្សាការសម្ងាត់យ៉ាងពេញលេញ។ ក្រុមការងាររបស់យើងខ្ញុំអាចផ្តល់ប្រឹក្សាលើជម្រើសទាំងអស់ជូនអ្នក ដើម្បីប្រាកដថាដំណោះស្រាយកម្ចីបង់រំលស់ថ្លៃសាកលវិទ្យាល័យ ADVANCE បំពេញតាមតម្រូវការជាក់លាក់របស់អ្នក។ ដើម្បីបំពេញពាក្យស្នើសុំរបស់អ្នក អ្នកនឹងត្រូវផ្តល់ឯកសារដែលបង្ហាញដូចខាងក្រោម។

### ឯកសារដែលត្រូវការសម្រាប់ដំណើរការកម្ចី
ជនជាតិខ្មែរ

| និយោជិក |
|---|
| អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន |
| សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬកិច្ចសន្យាជួលផ្ទះ |
| កិច្ចសន្យាការងារ ឬលិខិតបញ្ជាក់ការងារ |
| លិខិតបញ្ជាក់ប្រាក់ខែ 3-6 ខែចុងក្រោយ ឬរបាយការណ៍ធនាគារ រយៈពេល 3-6 ខែចុងក្រោយរបស់អ្នក ប្រសិនបើមាន។ |

| អាជីវករ (ប្រកបអាជីវកម្មផ្ទាល់ខ្លួន) |
|---|
| អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន |
| សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬកិច្ចសន្យាជួលផ្ទះ |
| អាជ្ញាប័ណ្ណអាជីវកម្ម ប៉ាតង់ ឬការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានរបស់អ្នក (បើមាន) |
| របាយការណ៍ប្រាក់ចំណូល វិក្កយបត្រ សៀវភៅធនាគារ របាយការណ៍បញ្ជាក់ចំណូលជា Excel |
| កិច្ចសន្យាជួល (ប្រសិនបើមាន) |
| របាយការណ៍ធនាគាររយៈពេល 3-6 ខែចុងក្រោយ |

### ឯកសារដែលត្រូវការសម្រាប់ដំណើរការកម្ចី
ជនជាតិបរទេស

បន្ថែមពីលើបញ្ជីខាងលើ ខាងក្រោមនេះជាតម្រូវការបន្ថែម និងមិនកំណត់ចំពោះអតិថិជនបរទេសទេ៖

| |
|---|
| ទិដ្ឋាការមានសុពលភាពរយៈពេល 6 ខែ |
| មានប្រាក់ចំណូលទៀងទាត់ ហើយមានគម្រោងស្នាក់នៅពីរយៈពេលមធ្យមទៅរយៈពេលវែងក្នុងប្រទេសកម្ពុជា |

ទូរសព្ទឥឡូវនេះ

## ធនាគារដែលអ្នកអាចទុកចិត្តបាន

ធនាគារ ប្រេដ ខេមបូឌា គឺជាធនាគារអឺរ៉ុបតែមួយគត់នៅព្រះរាជាណាចក្រកម្ពុជា។ យើងខ្ញុំជាផ្នែកមួយនៃក្រុមសម្ព័ន្ធ BRED Group ដែលជាក្រុមធនាគារធំបំផុតទីពីរនៅប្រទេសបារាំង ដោយមានអតិថិជនជាងមួយលាននាក់នៅទូទាំងពិភពលោក ព្រមទាំងបានជួយដល់ក្រុមគ្រួសារជាច្រើនសម្រេចបាននូវគោលដៅហិរញ្ញវត្ថុរបស់ពួកគេអស់រយៈពេលជាង 100 ឆ្នាំមកហើយ។

ចាប់តាំងពីការបើកដំណើរការនៅឆ្នាំ 2017 មក ធនាគារមានភាពរីកចម្រើនយ៉ាងឆាប់រហ័ស ហើយឥឡូវនេះយើងខ្ញុំមានបណ្តាញសាខាចំនួន 15 នៅរាជធានីភ្នំពេញ សៀមរាប បាត់ដំបង និងកំពង់ចាម ដែលផ្តល់ជូនអតិថិជននូវស្តង់ដាខ្ពស់បំផុតលើការធានាសុវត្ថិភាព និងសេវាធនាគារផ្ទាល់ខ្លួន រួមជាមួយនឹងធនាគារឌីជីថលដ៏ទាន់សម័យ។

## ស្នើសុំកម្ចីបង់រំលស់ថ្លៃសាកលវិទ្យាល័យ **ADVANCE** ថ្ងៃនេះ

ទូរសព្ទឥឡូវនេះ ឬ អ៊ីម៉ែលឥឡូវនេះ

ឬពិភាក្សាជាមួយក្រុមការងាររបស់យើងខ្ញុំ។

តាមដានយើងខ្ញុំនៅលើ៖

**BRED Bank (Cambodia) Plc.** | Registration: 00002982 | Postal Code: 12210
Head Office: No. 30, Preah Norodom Boulevard, Sangkat Phsar Thmey 3, Khan Daun Penh, Phnom Penh, Cambodia.
Freephone: **1800 20 1234** | International: **+855 23 999 222** | **bredcambodia.com**